# ការបង្រៀនអំពីពិធីបុណ្យជ្រមុជទឹក និងសាក្រាម៉ង់ នៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ២០

## ផ្នែកទី ១ ៖ លក្ខណៈសម្បត្តិដើម្បីទទួលបុណ្យជ្រមុជទឹក

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ២០:៣៧ ដោយរកមើលអ្វីដែលមនុស្សម្នាក់ត្រូវធ្វើដើម្បីមានលក្ខណៈគ្រប់គ្រាន់ទទួលពិធីបុណ្យជ្រមុជទឹក ។

បើចាំបាច់ សូមរកមើលនិយមន័យសម្រាប់ពាក្យដែលអ្នកមិនយល់ ។ បន្ទាប់មក សូមរាយបញ្ជីលក្ខណៈសម្បត្តិដើម្បីទទួលពិធីបុណ្យជ្រមុជទឹកក្នុងចន្លោះខាងក្រោម ។ អ្នកអាចនិយាយឡើងវិញខ្លះៗតាមពាក្យពេចន៍របស់អ្នកផ្ទាល់ ។

---

---

---

- តើតម្រូវការទាំងនេះបង្រៀនអ្នកអ្វីខ្លះអំពីព្រះអម្ចាស់ និងព្រះរាជបំណងប្រាថ្នារបស់ទ្រង់ដើម្បីប្រទានពរដល់យើង ?
- តើវាអាចមានអត្ថប្រយោជន៍យ៉ាងណាក្នុងការចងចាំតម្រូវការទាំងនេះ សូម្បីតែបន្ទាប់ពីយើងបានទទួលពិធីបុណ្យជ្រមុជទឹកហើយក្ដី ?

សូមជ្រើសរើសតម្រូវការពីរ ឬបីដែលបានរាយក្នុង ខទី ៣៧ ។ សូមពិភាក្សាអំពីរបៀបដែលការខិតខំបំពេញតាមតម្រូវការទាំងនេះឲ្យបានខ្ជាប់ខ្ជួនអាចជួយអ្នកឲ្យកាន់តែបានដូចជាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។

## ផ្នែកទី ២ ៖ តម្រូវការទាំងឡាយបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ២០:៦៨–៦៩ ដោយស្វែងរកការរំពឹងទុករបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ៗ បន្ទាប់ពីយើងបានទទួលពិធីបុណ្យជ្រមុជទឹក ។

- តើអ្នករៀនអ្វីខ្លះចេញពី ខទី ៦៩ អំពីរបៀបដែលយើងបង្ហាញភាពស័ក្តិសមរបស់យើងដល់ព្រះអម្ចាស់ បន្ទាប់ពីយើងទទួលពិធីបុណ្យជ្រមុជទឹកហើយ ?

សូមពិចារណាគូសចំណាំឃ្លា « ដំណើរ និងវាចាដ៏សុចរិត » នៅក្នុង ខទី ៦៩ ។ មនុស្សម្នាក់អាចបង្ហាញពី « ដំណើរ និងវាចាដ៏សុចរិត » តាមរយៈទង្វើ អាកប្បកិរិយា និងពាក្យសម្ដីដែលស្របនឹងព្រះ ។

- តើអ្នកគិតថាមានហេតុផលអ្វីខ្លះ ដែលព្រះអម្ចាស់ចង់ឲ្យសមាជិកនៃសាសនាចក្ររបស់ទ្រង់បង្ហាញ « ដំណើរ និងវាចាដ៏សុចរិត » បន្ទាប់ពីពួកគេបានទទួលពិធីបុណ្យជ្រមុជទឹកហើយ ?

សូមពិភាក្សាយ៉ាងហោចណាស់ឧទាហរណ៍ជាក់លាក់ចំនួនបី ពីរបៀបដែលយើងអាចបង្ហាញ « ដំណើរ និងវាចាដ៏សុចរិត » នៅក្នុងជីវិតរបស់យើងបាន ។ អ្នកក៏អាចពិភាក្សាអំពីឧទាហរណ៍នៃរបៀបដែលអ្នកបានព្យាយាមបង្ហាញអ្វីៗទាំងនេះនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នកផងដែរ ។

## ផ្នែកទី ៣ ៖ ការទទួលទានសាក្រាម៉ង់

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ២០:៧៥ ដោយរកមើលការណែនាំរបស់ព្រះអម្ចាស់អំពីពិធីបរិសុទ្ធនៃសាក្រាម៉ង់ ។

- ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងជួបជាមួយគ្នារាល់សប្ដាហ៍ដើម្បីទទួលទានសាក្រាម៉ង់ ?

ខទី ៧៧ និង ៧៩ មាននូវការអធិស្ឋានដែលព្រះអម្ចាស់បានណែនាំដល់អ្នកកាន់បព្វជិតភាពឲ្យពោល នៅពេលចាត់ចែងសាក្រាម៉ង់ ។ តាមរយៈពិធីបរិសុទ្ធនៃសាក្រាម៉ង់ យើងរំឭកសេចក្ដីសញ្ញា ដែលយើងធ្វើ ពេលយើងត្រូវបានជ្រមុជទឹក និងបញ្ជាក់ ។ នៅពេលយើងខិតខំរក្សាសេចក្ដីសញ្ញារបស់យើង ហើយប្រែចិត្តជារៀងរាល់ថ្ងៃ នោះយើងអាចដកពិសោធន៍នូវការសម្អាត និងពរជ័យដូចគ្នាដែលយើងបានដកពិសោធន៍តាមរយៈពិធីបុណ្យជ្រមុជទឹក ។

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ២០:៧៧ និង ៧៩ ដោយរកមើលអ្វីដែលយើងសន្យា និងអ្វីដែលព្រះអម្ចាស់សន្យា នៅពេលយើងទទួលទានសាក្រាម៉ង់ ។ សូមពិចារណាគូសចំណាំសេចក្ដីសន្យាទាំងនេះនៅក្នុងព្រះគម្ពីររបស់អ្នក ។

- តើយើងអាចបង្ហាញពីឆន្ទៈរបស់យើងដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?
- តើមានរបៀបអ្វីខ្លះដែលយើងអាចបង្ហាញព្រះអង្គសង្គ្រោះថាយើងចងចាំទ្រង់ ?

តើពិធីបរិសុទ្ធនៃសាក្រាម៉ង់ទាំងនេះបង្ហាញសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះចំពោះយើងដោយរបៀបណា ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2023 by Intellectual Reserve, Inc. All rights reserved. PD80007812_258_112-1